# ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាប្រទីបក្នុងលោក

ពុទ្ធោ តិលោកទីបោវ, ពុទ្ធោ សុរិយោ តមោនុទោ;
យេ យន្តិ សរណំ ពុទ្ធំ, នត្ថិ តេសំ ភយំ សទា ។

*ព្រះពុទ្ធជាប្រទីបក្នុងត្រៃលោក ព្រះអង្គដូចជាព្រះអាទិត្យ អាចកម្ចាត់បង់នូវងងឹតគឺអវិជ្ជា, ជនទាំងឡាយឯណាបានដល់ព្រះពុទ្ធជាទីពឹងទីរលឹក, ភ័យមិនមានដល់ជនទាំងឡាយនោះសព្វៗកាល ។*

ធម្មោ តិលោកទីបោវ, ធម្មោ សុរិយោ តមោនុទោ;
យេ យន្តិ សរណំ ធម្មំ, នត្ថិ តេសំ ភយំ សទា ។

*ព្រះសទ្ធម្មជាប្រទីបក្នុងត្រៃលោក ព្រះសទ្ធម្មនោះឯងជាព្រះអាទិត្យ អាចកម្ចាត់បង់នូវសេចក្តីងងឹត គឺអវិជ្ជា, ជនទាំងឡាយឯណា បានដល់នូវព្រះសទ្ធម្មជាទីពឹងទីរលឹក, ភ័យមិនមានដល់ជនទាំងឡាយនោះសព្វៗកាល ។*

សង្ឃោ តិលោកទីបោវ, សង្ឃោ សុរិយោ តមោនុទោ;
យេ យន្តិ សរណំ សង្ឃំ, នត្ថិ តេសំ ភយំ សទា ។

*ព្រះសង្ឃជាប្រទីបក្នុងត្រៃលោក ព្រះសង្ឃនោះឯងជាព្រះអាទិត្យ អាចកម្ចាត់បង់នូវងងឹត គឺអវិជ្ជា ជនទាំងឡាយឯណា បានដល់នូវព្រះសង្ឃជាទីពឹងទីរលឹក ភ័យមិនមានដល់ជនទាំងឡាយនោះសព្វៗកាល ។*

យោ ច ពុទ្ធញ្ច ធម្មញ្ច, សង្ឃញ្ច សរណំ គតោ;
អបទីបោ ន ភវេយ្យ, អធិគច្ឆេយ្យ បទំ សុខំ ។

*បើនរណាមួយ បានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរលឹកហើយ, នរជននោះ ឈ្មោះថាជាអ្នកមានប្រទីប គឺបញ្ញា ហើយបាននូវព្រះនិព្វានជាបរមសុខដ៏ក្រៃលែង ។*

*(ទុលកបណ្ឌិតជាតក បញ្ញាសជាតក)*

*ដោយសជវថ*